ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ៤២៦ មស.ករក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមអ្នកនាំពាក្យនិងក្រុមការងារបណ្តាញទំនាក់ទំនងសង្គម នៃក្រសួងមុខងារសាធារណៈ

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៦/១២១៣/ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញសេចក្តីណែនាំចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ១ .-**

បង្កើតក្រុមអ្នកនាំពាក្យនៃក្រសួងមុខងារសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **យត់ ប៊ុនណា** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **ជុក មុន្នី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៣- ឯកឧត្តម **ឈឿន ប៊ុណ្ណារ័ត្ន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៤- ឯកឧត្តម **គង់ សុគី** | អគ្គនាយក | សមាជិក |
| ៥- ឯកឧត្តម **ស សាម៉ីឌី** | ទីប្រឹក្សានិងជាប្រធាននាយកដ្ឋាន | សមាជិក |
| ៦- ឯកឧត្តម **ពេជ្រ វិជ្ជាគន្ធី** | អគ្គនាយក | សមាជិក |
| ៧- ឯកឧត្តម **អុល រ៉ូ** | អគ្គនាយក | សមាជិក |

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| | | |
|---|---|---|
| ៨- លោក **សិត ហេងឡុង** | ប្រធានមជ្ឈមណ្ឌល | សមាជិក |
| ៩- លោកស្រី **តឹក កុសុមា** | អនុប្រធាននាយកដ្ឋាន | សមាជិក។ |

ក្រុមអ្នកនាំពាក្យនេះ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ទំនាក់ទំនងនិងឆ្លើយឆ្លងជាផ្លូវការជាមួយសាធារណៈជននិងបណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិពាក់ព័ន្ធវិស័យមុខងារសាធារណៈ
- ប្រមូលព័ត៌មាន និង ឯកសារពាក់ព័ន្ធតាមគ្រប់មធ្យោបាយ ដើម្បីឆ្លើយបំភ្លឺជាមួយសាធារណៈជននិងបណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិ
- រៀបចំសន្និសីទសារព័ត៌មាននានាជូនថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ
- ផ្តល់យោបល់និងតម្រង់ទិសដល់ក្រុមការងារបណ្តាញទំនាក់ទំនងសង្គមនៃក្រសួងមុខងារសាធារណៈ ដើម្បីដោះស្រាយ និង ឆ្លើយតបនឹងសម្រង់ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈដែលទទួលបានពី Facebook សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបណ្តាញទំនាក់ទំនងសង្គមផ្សេងទៀត។
- ទទួលភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

**ប្រការ២ ..**

បង្កើតក្រុមការងារបណ្តាញទំនាក់ទំនងសង្គមនៃក្រសួងមុខងារសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ឈឿន ប៊ុណ្ណារ័ត្ន** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២- លោក **ឈុន សុជាតិ** | អគ្គនាយករង | សមាជិក |
| ៣- លោក **ឡុង សារឿន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៤- លោក **ឫទ្ធី សុគន្ធារិទ្ធ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៥- លោក **ម៉េង ម៉េងឥត** | ប្រធាននាយកដ្ឋាន | សមាជិក |
| ៦- លោក **ប៉ែន ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧- លោក **អេង សុចិរៈ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨- លោក **សយ ចិសាល** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៩- លោក **ឱត និមល** | ប្រធានការិយាល័យ | សមាជិក |

ក្រុមការងារខាងលើនេះ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ប្រមូល និង ចងក្រងរាល់ព័ត៌មានពាក់ព័ន្ធវិស័យមុខងារសាធារណៈដែលមានក្នុង Facebook សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងពីបណ្តាញទំនាក់ទំនងសង្គមផ្សេងៗទៀត ដាក់ជូនក្រុមអ្នកនាំពាក្យនៃក្រសួងមុខងារសាធារណៈ ពិនិត្យ រកដំណោះស្រាយ និងផ្តល់យោបល់ឆ្លើយតបឱ្យបានទាន់ពេលវេលា
- ជួយសម្រួលការងារទាំងឡាយពាក់ព័ន្ធនឹងដំណោះស្រាយ ឬ ផ្តល់ចម្លើយតបនានាតាមបណ្តាញទំនាក់ទំនងសង្គមឱ្យបានទាន់ពេលវេលា

- ទទួលយកមតិយោបល់និងដំណោះស្រាយនានាពីក្រុមអ្នកនាំពាក្យនៃក្រសួងមុខងារសាធារណៈ ដើម្បីឆ្លើយតបនឹងសម្រង់ព័ត៌មានពី Facebook របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងពីបណ្តាញទំនាក់ទំនងសង្គមផ្សេងៗទៀត
- រៀបចំផ្តល់យោបល់ឆ្លើយតបឬដំណោះស្រាយឱ្យបានទាន់ពេលវេលានូវរាល់សម្រង់ព័ត៌មានពាក់ព័ន្ធវិស័យមុខងារសាធារណៈដែលទទួលបាន។

**ប្រការ៣ .-**

ក្រុមការងារទាំងពីរខាងលើ មានសិទ្ធិសហការជាមួយអង្គភាពនានានៃក្រសួងមុខងារសាធារណៈនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អប្រសើរ។

ប្រធានក្រុមអ្នកនាំពាក្យក្រសួងមុខងារសាធារណៈ មានសិទ្ធិអញ្ជើញសមាជិកទាំងអស់ ដូចមានកំណត់ក្នុងប្រការ១និងប្រការ២ ចូលរួមប្រជុំតាមការកំណត់។

**ប្រការ៤ .-**

សេចក្តីសម្រេចលេខ៣៩៦២ មស.នក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមអ្នកនាំពាក្យនៃក្រសួងមុខងារសាធារណៈ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ នាយកសាលាភូមិន្ទរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋានមុខងារសាធារណៈ គ្រប់អង្គភាពក្រោមឱវាទក្រសួងមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១និងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ (ដើម្បីជូនជ្រាប)
- ដូចប្រការ៥(ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ